# កុលស្ត្រី

## កុលធីតាផ្ការោយ

សូមឧទ្ទិសរឿងនេះជូនប្អូនស្រី «រដ្ឋនី» ដែលបានស្នើសុំបងឲ្យសរសេររឿងនេះឡើង
និងសុំទោសផងចំពោះការយឺតយូរ...

«ហេតុអី ពិន្ទុរបស់ឯងអន់ដល់ថ្នាក់នេះ រដ្ឋនី?» សំឡេងរបស់បុរសវ័យកណ្ដាលមនុស្សលាន់ខ្ទរដេរកូនស្រីដោយក្ដីក្រេវក្រោធ «យើងបញ្ជូនឯងឲ្យទៅរៀន មិនមែនឲ្យទៅដើរលេងទេ មុននឹងធ្វើអីឲ្យគិតដល់កិត្តិយសវង្សត្រកូលផង! តើភាពជាកុលស្ត្រីរបស់ឯង មានខ្លះទេ?»

ស្រស់ស្រីសម្លឹងមុខបិតាដោយក្ដីតូចចិត្ត។ នៅក្នុងខ្សែភ្នែកអ្នកដទៃ នាងកើតមកនៅក្នុងគ្រួសារដែលបរិបូរគ្រប់បែបយ៉ាង... តែសម្រាប់នាង... មិនមែនទេ!

«ពេលដែលម៉ាក់របស់ឯងស្លាប់ ប៉ាសន្យាជាមួយខ្លួនឯងថា នឹងមើលថែឯងឲ្យល្អ!... តែនេះស្អីគេ? ឯងគិតតែដើរលេង ដេកស៊ី លេងអ៊ីនធើណេត និយាយទូរស័ព្ទ ហើយតែងខ្លួនលេចលើលេចក្រោម ប្រណាំងប្រជែងជាមួយអ្នកក្រុងមិនឈប់មិនឈរ... ឯងសាកយកទៅគិតមើលខ្លួនឯងទៅថាសមគួរទេដែលមកកើតក្នុងត្រកូលខ្ពង់ខ្ពស់របស់ប៉ា!?»

រដ្ឋនី សម្លឹងមុខលោកប្រសិទ្ធិជាបិតាដោយភ្នែកមាំ «មួយម៉ាត់ណាក៏មុខមាត់របស់វង្សត្រកូល ពីរម៉ាត់ណាក៏កូនឥតបានការ... តើនៅក្នុងខ្សែភ្នែករបស់ប៉ា ខ្ញុំធ្លាប់មានអ្វីល្អៗខ្លះទេ?» នាងដាក់មុខចុះវិញ ព្រមជាមួយសំឡេងខ្សោយជាងមុន «ខ្ញុំដឹងថាខ្ញុំមិនល្អ រៀនក៏មិនពូកែ ធ្វើអ្វីក៏មិនបាន... តែកូនក៏មានបេះដូងដែរប៉ា!»

«ចុះឯងមានធ្លាប់គិតដល់បេះដូងរបស់ប៉ាខ្លះទេ កូននី!? មួយថ្ងៃៗ ឯងគិតតែដើរលេង តែងខ្លួនលេចលើលេចក្រោម ឯងដឹងទេ ថាប៉ាលក់មុខខ្លាំងប៉ុណ្ណា នៅពេលមានគេមកសួរនាំ?» គាត់ច្រត់ចង្កេះសួរកូនដោយក្ដីអត់ធន់ហួសប្រមាណ។

«ចាស ត្រូវហើយ! ខ្ញុំជាកូនអាក្រក់ ជាកូនចង្រៃឧត្បាត... ពេលដែលខ្ញុំកើតមកក៏ធ្វើឲ្យម៉ាក់ស្លាប់! ពេលមានជីវិតរស់នៅ ក៏ធ្វើឲ្យប៉ាពិបាកចិត្តទៀត... តើកូនសមតែស្លាប់ឲ្យបាត់ៗទៅ តើមែនទេ?!!» នាងស្រែកគំហកខ្លាំងៗដាក់មុខបិតា។

លោកប្រសិទ្ធិមុខក្រហមងាំង ខឹងកូនស្រីហួតញ័រខ្លួន។ គាត់ស្រលាញ់កូនស្រីម្នាក់នេះខ្លាំងណាស់... តែមិនដឹងថាព្រោះកម្មពៀអ្វី ទើបធ្វើឲ្យគាត់មកជួបនឹងកូនស្រីដែលអាក្រក់រកលេខដាក់គ្មានបែបនេះ។

ផាំង!!!

គាត់ទះកំផ្លៀងកូនស្រី...

រដ្ឋនី រាមុខទៅតាមកម្លាំងដៃ... ទឹកភ្នែកស្រក់ប៉ាត់ៗដោកថ្ពាល់។

«នេះឬ អ្នកដែលជាម្ចាស់មូលនិធិសមាគមក្មេងកំព្រាកម្ពុជា?... នេះឬ អ្នកដែលឈរឈ្មោះបោះឆ្នោតជាតំណាងរាស្ត្រនៅឆ្នាំក្រោយ?» នាងរម្លឹកដល់តួនាទីការងារ របស់បិតាដោយក្តីឈឺចិត្ត «តាំងពីតូចដល់ធំ... ប៉ាតែងតែទូន្មានកូនឲ្យតាំងចិត្តរៀន ឲ្យខំរៀនឲ្យបានខ្ពស់ៗ ដើម្បីក្លាយជាលោកស្រី ក្លាយជាជំទាវនៅអនាគត... តែប៉ាធ្លាប់គិតដល់ចិត្តកូនខ្លះទេ? ធ្លាប់សួរឬទេ ថាកូនមានបញ្ហាអីឬអត់?... មួយថ្ងៃៗ ប៉ាឲ្យកូនបានត្រឹមតែលុយចាយវាយ... តែប៉ាបែរជាយកពេលវេលា សេចក្តីស្រលាញ់ ការមើលថៃ ការយកចិត្តទុកដាក់ ទៅឲ្យក្មេងកំព្រានៅក្នុងមូលនិធិទាំងអស់... ជួនកាលកូននៅនឹកប្រណែននឹងក្មេងកំព្រាអស់ទាំងនោះផង... ប៉ាមិនដែលដឹងសូម្បីតែបន្តិចសោះថា អ្វីដែលក្មេងស្រីដូចកូន ត្រូវការជាទីបំផុត?»

គាត់ខឹងកូនស្រីកាន់តែខ្លាំងឡើង នៅពេលត្រូវកកូរកកាយដល់តួនាទីការងារ... ខ្សែភ្នែកកាចមាំសម្លឹងយ៉ាងមុតមកចំកូនស្រី។

«មុខដូចឯង តើទៅត្រូវការអី... យើងឃើញមួយថ្ងៃៗ ឯងគិតតែយកពេលទៅដើរលេងអាវ៉ាសែ ... ក្មេងស្រីដូចឯង តើចេះត្រូវការអីក្រៅពីប្រុស!» បុរសជាបិតាគំហកខ្ទរសំឡេងពេញផ្ទះ «អ្វីដែលប៉ាគួរឲ្យឯង ប៉ាក៏ឲ្យអស់គ្រប់យ៉ាងហើយដែរ តែក្មេងកំព្រាទាំងនោះទេ ដែលមិនធ្លាប់បានអ្វីសោះពីឪពុកម្តាយ... ខណៈដែលឯងមានគ្រប់បែបយ៉ាងលើសក្មេងទាំងនោះ តែឯងបែរជាធ្វើឲ្យប៉ាលក់មុខលក់មាត់ខ្មាសគេអស់ម៉ាទីក្រុង... បើយើងអាចរើសបាន យើងចង់យកក្មេងកំព្រាទាំងនោះ មកធ្វើជាកូនជំនួសឯងផង!»

«សូមប៉ា ឈប់យកខ្ញុំទៅប្រៀបធៀប នឹងក្មេងកំព្រាអស់នោះទៅ!» នាងនិយាយលាយឡំភាពខ្សឹកខ្សួល «បើប៉ាមើលមកខ្ញុំជាមេបង្ករឿង ឃើញក្មេងកំព្រាអស់នោះល្អជាងខ្ញុំ ក៏អញ្ជើញទៅយកក្មេងទាំងនោះមកធ្វើជាកូនចុះ! បំភ្លេចខ្ញុំចោលតែម្តងក៏បាន យ៉ាងណាខ្ញុំក៏គ្មានតម្លៃស្រាប់ទៅហើយ!» នាងគំហកដាក់បិតាទាំងទឹកភ្នែក។

រដ្ឋនី ទុកសៀវភៅពិន្ទុចោលនៅលើតុ មុននឹងស្ទុះគេចចេញទៅសម្ងំលាក់ខ្លួនក្នុងបន្ទប់ខ្ទាស់គន្លឹះជាប់... «ប៉ា... ប៉ាមិនធ្លាប់យល់ពីកូនសោះ... កូនស្អប់ប៉ា ស្អប់ជាទីបំផុត!!» នាងពោលខ្សឹកខ្សួលទាំងទឹកភ្នែក។

លោកប្រសិទ្ធិ៍ជាឪពុក សម្លឹងស្រមោលកូនស្រីដែលរត់ចូលបន្ទប់ យ៉ាងហេងហាង... នៅក្រោមខ្សែភ្នែកដ៏មុតមាំនោះ បែរជាមានបង្កប់ភាពឈឺចាប់នៅខាងក្នុង យ៉ាងស្មានមិនត្រូវ...

គាត់សម្លឹងមើលបាតដៃខ្លួនឯងដែលទើបតែទះមុខកូនស្រីទៅថ្មីៗយ៉ាងដឹងកំហុស។

«ប៉ា... ប៉ាសុំទោស...»

* * *

រដ្ឋនី ខ្សឹកខ្សួលអង្គុយឱបក្បាលជង្គង់ ត្រង់ជ្រុងបន្ទប់ដេកដោយក្តីឈឺចាប់។ នាងលូកដៃសន្សឹមៗចាប់យកទូរស័ព្ទដៃចុចទៅលេខវីរៈ... សង្សារកំលោះដែលទើបតែស្គាល់គ្នាតាមហ្វេសប៊ុកថ្មីៗនេះ។

ទោះបីជាដឹងថា វាជារឿងដែលគ្មានសុវត្ថិភាព ក្នុងការទាក់ទងស្វែងយល់ចិត្តជាមួយមិត្តភក្តិតាមអ៊ីនធើណេត តែនៅពេលស្ថានការណ៍ចាប់បង្ខំបែបនេះ... នាងក៏គ្មានអ្វីត្រូវខ្វល់ច្រើនទៀតដែរ។

«អាឡូ! បងវីរៈ បងជួយមកទទួលអូននៅផ្ទះបន្តិចបានទេ? នីមិនចង់នៅទីនេះទៀតទេ!» នាងយំអណ្តឺតអណ្តក ឲ្យចុងខ្សែម្ខាងទៀតស្តាប់ដោយមិនរារែក នៅពេលបានទទួលសញ្ញាណ។

បុរសនៅចុងខ្សែម្ខាងទៀត ខណៈនេះកំពុងផឹកស្រា ស្រវឹងគ្រឿងញៀនជាមួយក្រុមមិត្តភក្តិ ប្រញាប់ពាក់ស្រោមមុខសម្តែងតួជាសុភាពបុរស និងបញ្ចូលសំឡេងម៉ឺងម៉ាត់ជាបន្ទាន់។

«អូននី... អូននីកើតអី? រត់ចេញពីផ្ទះមិនល្អទេណា ដឹងទេ?» គេធ្វើជានិយាយហាមប្រាមសម្តែងឫកពាជាបារម្ភនឹងសង្សារយ៉ាងពុតត្បុត។

«អត់ទេ! ទោះនីជាក្មេងល្អយ៉ាងណា ក៏ប៉ាមើលមិនឃើញដែរ... ណាបងវីរៈ ជួយមកទទួលនីចេញពីផ្ទះនេះផង! នីទុកចិត្តបងរះណា នីមិនចង់នៅទីនេះទៀតទេ... ព្រោះទាំងតឹងតែង ទាំងរងការកៀបសង្កត់ នីធុញទ្រាន់នឹងនៅឈ្លោះគ្នា ជាមួយប៉ារាល់ថ្ងៃបែបនេះទៀតណាស់!»

វីរៈ ងាកមកញញឹមពព្រាយដាក់មិត្តភក្តិយ៉ាងមានគំនួច «ចុះអូននីចង់ទៅនៅឯណា?»

នាងជូតទឹកភ្នែកចេញពីថ្ពាល់យ៉ាងរហ័ស ហាក់មានកម្លាំងចិត្តជាថ្មី «ទីណាក៏បាន... ទីដែលគ្មានប៉ា គ្មានមនុស្សដែលស្គាល់នី គ្មានមនុស្សដែលចាំតែបំបាក់ទឹកចិត្តនី... គ្រាន់តែនាំនីរត់ចេញទៅឲ្យឆ្ងាយបំផុតពីផ្ទះនេះ... នីក៏អស់ចិត្តហើយ!»

«អ៊ីចឹង... បានតើ! បងស្រលាញ់អូននីអស់ពីចិត្ត បងធ្វើដើម្បីអូននីបានគ្រប់យ៉ាង ថ្វីបើយើងស្គាល់គ្នាតាមអ៊ីនធើណេត តែបងហ៊ាននិយាយយ៉ាងពេញមាត់ថា បងស្រលាញ់នី! ឥឡូវអូននីប្រញាប់រៀបចំអីវ៉ាន់ទៅរង់ចាំបងនៅច្រកផ្លូវចេញចុះ មិនដល់ដប់នាទីទៀត បងនឹងទៅទទួល!» គេចុចទូរស័ព្ទបិទ ហើយញញឹមចុងមាត់យ៉ាងមានពិសពុល។

រដ្ឋនីប្រញាប់រត់ទៅប្រមូលសម្លៀកបំពាក់ របស់របរ គ្រឿងប្រើប្រាស់ផ្សេងៗដាក់ក្នុងកាបូបស្ពាយយ៉ាងរហ័សរហួន មុននឹងលោតចុះតាមបង្អួច ហើយផ្លោះរបងចេញពីផ្ទះទៅដោយលោកប្រសិទ្ធិ៍កំពុងដេកលង់លក់យ៉ាងស្កប់ស្កល់ក្នុងបន្ទប់ដេកដោយមិនដឹងរឿង...

ទ្រីន...

វីរៈ បើករថយន្តចូលមកចតក្បែរស្រី ដោយមិនអែរអង់។ ដោយការទុកចិត្តបែបគ្មានវិចារណ-ញ្ញាណ រដ្ឋនីប្រញាប់រត់ចូលទៅអង្គុយក្បែរបាំងអ្នកបើក ដោយមិនអល់អែក។ អ្នកទាំងពីរញញឹមដាក់គ្នាដោយក្តីស្នេហា។

«បងវីរៈ គិតចង់នាំនីទៅណា?» នាងសួរដូចកូនក្មេងមិនទាន់ដឹងអី។

វីរៈ ងាកមុខមកញញឹមស្រទន់ដាក់សង្សារ «បងនឹងនាំអូននី ទៅរកញាតិមិត្តបង! ចៃដន្យអី ពួកគាត់បើកសណ្ឋាគារនៅម្តុំវង្គសាល ដែលបងចូលចិត្តទៅកម្សាន្តលេងញឹកញាប់ជាមួយមិត្តភក្តិ។ បើនីទៅនៅទីនោះ ធានាថាមានសុវត្ថិភាពមួយរយភាគរយតែម្តង!»

«អរគុណបងវីរៈខ្លាំងណាស់... នីពិតជារំភើបនឹងទឹកចិត្តសុភាពបុរស របស់បងមែនទែន!» ស្រស់ស្រីស្ងប់ស្ងែងនឹងសន្តានចិត្តសង្សារកាន់តែជ្រៅទៅៗ។

* * *

«កូននី! កូនទៅណាហើយ?» លោកប្រសិទ្ធ តាមរកកូនស្រីខ្លួនឯងពេញផ្ទះ... គាត់ចាប់ផ្តើមទទួលអារម្មណ៍មិនស្ងួវស្រួល និងញាប់ញ័រក្នុងចិត្ត ព្រោះបារម្ភពីកូនស្រីតែម្នាក់របស់ខ្លួន។

គាត់រត់ទៅប្តឹងប៉ូលីសជាបន្ទាន់... ព័ត៌មានចេញផ្សាយតាមកាសែតព្រោងព្រាត **«កូនស្រីរបស់ពាណិជ្ជករធំរត់ចេញពីផ្ទះ!»** គាត់អាប់មុខអាប់មាត់លក់កេរ្តិ៍ឈ្មោះកិត្តិយសខាងផ្នែកសង្គមយ៉ាងខ្លាំង ដោយនរណាៗក៏នាំគ្នាសម្លឹងមកថា គាត់គឺជាបិតានៃក្មេងកំព្រា តែត្រលប់ក្លាយជាឪពុកដែលចិញ្ចឹមកូនមិនកើត បណ្តោយឲ្យកូនស្រីរត់ចេញពីផ្ទះបានយ៉ាងងាយស្រួល។

អ្នកភ្នំពេញនាំគ្នាយកព័ត៌មាននេះ មកធ្វើជាប្រធានបទជជែកវែកញែក អស់ជាច្រើនថ្ងៃ។ បុរសវ័យកណ្តាលមនុស្សខ្មាសគេឯង រហូតមិនដឹងយកមុខទៅទុកឯណា។ តែដោយសេចក្តីស្រលាញ់ សេចក្តីព្រួយបារម្ភចំពោះកូន គាត់ត្រូវតែដើរទទូរមុខតាមរកកូនស្រីគ្រប់ទិសទី រហូតមកដល់សាលារៀន...

«អ្នកគ្រូ មានជ្រាបពីដំណឹងរបស់រដ្ឋនី... កូនស្រីរបស់ខ្ញុំខ្លះទេ?» គាត់រត់ចូលយ៉ាងរហ័សទៅអង្គុយលើកៅអីទល់មុខអ្នកគ្រូរបស់រដ្ឋនី។

ទឹកមុខគាត់ខ្មៅស្លក់ ព្រោះមិនបានដេកអស់ពេលជាច្រើនថ្ងៃ... រាងកាយក៏ចុះស្គមស្គាំងប្លែកភ្នែក ដ្បិតទទួលទានបាយមិនចូលមួយថ្ងៃណាសោះ។

អ្នកគ្រូញញឹមផ្តល់កម្លាំងចិត្តឲ្យលោកប្រសិទ្ធ «នាងខ្ញុំមិនបានដំណឹងអ្វីពីរដ្ឋនីទេ... តែបើខ្ញុំដឹងពេលណា នាងខ្ញុំនឹងប្រាប់លោកជាបន្ទាន់!» អ្នកគ្រូនិយាយយ៉ាងសុភាពរាបសា។

លោកប្រសិទ្ធធ្លាក់ទឹកមុខអស់សង្ឃឹម «បាទ! អរគុណ...» គាត់បម្រុងនឹងក្រោកចេញដើម្បីទៅតាមរកកូនស្រីខ្លួនឯងបន្ត តែ...

«ឈប់សិនលោក!» អ្នកគ្រូឃាត់យ៉ាងសុភាព «នាងខ្ញុំសុំសាកសួរអ្វីលោកបន្តិចបានទេ?»

គាត់ងាកក្រោយសម្លឹងមុខអ្នកគ្រូដោយក្តីងឿងឆ្ងល់ «អឺ... បាទ បានតើ!»

«មុននឹងរដ្ឋនីរត់ចេញពីផ្ទះ តើមានកើតបញ្ហាអ្វីនៅក្នុងគ្រួសារឬទេ?» អ្នកគ្រូជ្រួញចិញ្ចើមសួរ។

បុរសជាឪពុកបើកភ្នែកធំៗដោយក្តីភ្ញាក់ផ្អើល មុននឹងអារម្មណ៍ប្រែជាសោកសៅដូចដើមវិញ «បាទ... ថ្ងៃនោះជាថ្ងៃដែលខ្ញុំទទួលសៀវភៅពិន្ទុពីនាង។ ពេលនោះខ្ញុំខឹងនាងខ្លាំងណាស់... យើងទាំង

ពីរប៉ះមាត់ប៉ះសម្ដីគ្នាបន្តិចបន្តួច ហើយខ្ញុំក៏ជ្រុលដៃទះកំផ្លៀងនាងដោយមិនបានតាំងចិត្ត!» គាត់ឈ្ងោកមុខចុះក្រោម គេចខ្សែភ្នែកពីអ្នកគ្រូដោយការដឹងខុស។

«ការពិតដើមហេតុនៃរឿងនេះ គឺមកពីពិន្ទុនេះទេឬ? លោកភ្លេចទៅហើយថា ការរៀនពូកែមិនមែនជាគ្រឿងវាស់ភាពជោគជ័យរបស់កូននោះទេ!» អ្នកគ្រូដកដង្ហើមធំ «ថ្វីបើរដ្ឋនីជាក្មេងដែលរៀនមិនពូកែ តែក៏មិនមែនបានន័យថា នាងជាក្មេងមិនល្អដែរ!»

«តែខ្ញុំត្រូវការប្រៀនប្រដៅវាណាអ្នកគ្រូ! អ្នកគ្រូក៏ដឹងថា មួយថ្ងៃៗវាមិនបានតាំងចិត្តរៀនទេ ព្រោះរវល់តែយកពេលទៅតែងខ្លួនឆើតឆាយ ប្រណាំងប្រជែងជាមួយមិត្តភក្តិរហូតស្ទើរតែមិនសេសសល់ភាពជាកុលស្ត្រីនៅក្នុងខ្លួនទៅហើយ!»

«ភាពជាកុលស្ត្រី តើគេវាស់វែងនៅត្រង់ណាទៅ?» អ្នកគ្រូសួរសំឡេងមាំ «អ្វីដែលបញ្ជាក់ប្រាប់លោកថា រដ្ឋនីមិនមែនជាកុលស្ត្រី?»

«គឺទង្វើរបស់វានោះអី! វាតែងខ្លួនលេចលើលេចក្រោម ចូលចិត្តដើរលេង ចូលចិត្តនិយាយទូរស័ព្ទ ហើយលួចមានសង្សារដោយស្ងាត់ៗ... នេះឬលក្ខណៈរបស់កុលស្ត្រី? បើខ្ញុំមិនហាមវា ថ្ងៃណាមួយ វាច្បាស់ជាខូចខ្លួនមិនខាន!» គាត់ប្រកែក។

«ចុះលទ្ធផលនៃការប្រៀនប្រដៅរបស់លោកយ៉ាងម៉េចដែរ? ពេលនេះនាងរត់ចេញពីផ្ទះទៅហើយ... ខ្ញុំដឹងថា លោកព្រួយបារម្ភពីរដ្ឋនីខ្លាំងណាស់ តែសូមកុំប្រើអារម្មណ៍ដើម្បីប្រៀនប្រដៅកូនអី... កូនរបស់លោក កំពុងឈានចូលមកក្នុងវ័យជំទង់ មានបញ្ហាជាច្រើនកំពុងសម្រុកចូលមករកនាង ក្មេងគេមិនអាចមកប្រាប់លោកបានគ្រប់រឿងនោះទេ... ហើយភាពជាកុលស្ត្រីដែលលោកថា តើត្រូវតែរៀបរយដូចសំពត់ក្នុងផ្នត់ឬ?... ឥឡូវនេះសង្គមបានប្រែប្រួលហើយ គ្រឿងអូសទាញផ្លូវចិត្តយុវវ័យមានច្រើនណាស់... ការជេរប្រដៅកាចៗបែបនោះ វាមិនបានធ្វើឲ្យរដ្ឋនីមានភាពជាកុលស្ត្រីល្អឡើងនោះទេ!»

លោកប្រសិទ្ធិស្លឹកមុខ... «ចុះអ្នកគ្រូចង់ឲ្យខ្ញុំអង្គុយមើលកូនស្រីខ្លួនឯង ធ្វើខ្លួនកាន់តែយ៉ាប់ទៅរាល់ថ្ងៃបែបនេះឬ?»

«កុំនិយាយបែបនេះអី... រដ្ឋនីមិនមែនយ៉ាប់ដូចដែលលោកគិតនោះទេ! ជួនកាលរូបភាពដែលលោកឃើញ អាចគ្រាន់តែជាផ្នែកមួយនៃជីវិតរបស់នាងក៏ថាបាន!» អ្នកគ្រូញញឹម «ក្មេងជំទង់ប្រៀបបាននឹងកូនឈើលាស់ខ្ចី ដែលកំពុងលូតលាស់ក្លាយជា មនុស្សពេញមនុស្ស... ក្មេងវ័យនេះ អាចមានអាកប្បកិរិយាប្រែប្រួលច្រើនយ៉ាង ហេតុដូចនេះយើងជាអាណាព្យាបាល ត្រូវព្យាយាមតាមដានមើលអាកប្បកិរិយារបស់កូនឲ្យបានម៉ត់ចត់។»

លោកប្រសិទ្ធិសម្លឹងមុខអ្នកគ្រូយ៉ាងស្លុតចិត្ត... ហាក់សោកស្ដាយនឹងទង្វើរបស់ខ្លួនកន្លងមក។

«លោកត្រូវដឹងថា ក្មេងគ្រប់រូបត្រូវការសេចក្ដីស្រលាញ់ពីឪពុកម្ដាយ... ជួនកាលទង្វើរបស់ឪពុកម្ដាយ ដែលតែងតែជេរស្ដីប្រដៅកូនអាក្រក់ៗ គឺដើម្បីចង់ឲ្យពួកគេល្អ ចេះកែប្រែខ្លួនឯង តែសម្រាប់ក្មេង គេមិនបានគិតបែបនោះទេ គេបែរជាគិតថាយើងមិនត្រូវការគេទើបស្ដីបន្ទោសគេដូច្នេះ!

នេះអាចជាហេតុផលមួយដែលធ្វើឲ្យរដ្ឋនីរត់ចេញពីផ្ទះបាន!» អ្នកគ្រូគ្រវីក្បាល សម្លឹងមុខបុរសជាឪពុក ដោយចិត្តត្រជាក់ «ហើយបញ្ហាដែលគ្រូដូចនាងខ្ញុំជួបញឹកញាប់បំផុតគឺ ការនិយាយប្រៀបធៀប! ក្មេងគ្រប់គ្នាសុទ្ធតែមានចំណុចពិសេសរបស់គេរៀងៗខ្លួន... ឧទាហរណ៍ថា បើនៅសុខៗស្រាប់តែមានគេយកឈ្មោះលោកទៅប្រៀបធៀបនឹងអ្នកដទៃដែលល្អជាង តើលោកទទួលអារម្មណ៍យ៉ាងណា?»

«ខ្ញុំ... ខ្ញុំ... ជាឪពុកដែលមិនល្អ!» បុរសជាបិតាចាប់ផ្ដើមខ្សឹកខ្សួល។

«លោកមិនខុសទេ ព្រោះការចិញ្ចឹមមើលថែកូនរបស់គ្រួសារនីមួយៗ មិនដូចគ្នាឡើយ នាងខ្ញុំយល់... តែចង់ឲ្យលោកទទួលដឹងនៅត្រង់ចំណុចនេះផងចុះថា... ក្មេងជំទង់ភាគច្រើនដែលរត់ចេញពីផ្ទះ គឺច្រើនតែរត់ចេញដោយសារបញ្ហាគ្រួសារ!»

«ខ្ញុំស្រលាញ់កូនខ្លាំងណាស់! គ្រប់យ៉ាងដែលខ្ញុំធ្វើទៅនេះ គឺដើម្បីគេទាំងអស់... ខ្ញុំមិននឹកស្មានថាបំណងល្អរបស់ខ្ញុំ បែរជាក្លាយជាថ្នាំពិស បំផ្លាញផ្លូវចិត្តកូនដល់ថ្នាក់នេះសោះ!»

«ឪពុកម្ដាយគ្រប់រូបស្រលាញ់កូន តែក្មេងភាគច្រើន មើលមិនឃើញសេចក្ដីស្រលាញ់នោះទេ... ព្រោះត្រូវសម្ដីប្រៀនប្រដៅកាចៗទាំងនោះបិទបាំង!» អ្នកគ្រូញញឹមផ្ដល់កម្លាំងចិត្តជាចុងក្រោយ មុននឹងក្រោកដើរចេញពីបន្ទប់ទៅ។

សម្ដីរបស់អ្នកគ្រូ ធ្វើឲ្យលោកប្រសិទ្ធិនឹកឃើញទៅដល់ ហេតុការណ៍នៅយប់នោះ... គាត់ទើបតែដឹងថា ទង្វើដែលគាត់ធ្វើទៅទាំងអម្បាលម៉ាន គឺសុទ្ធតែផ្ដល់ផលអាក្រក់ចំពោះកូនទាំងអស់ ព្រោះគាត់ទាំងវាយ ទាំងជេរ ទាំងមើលងាយ ទាំងប្រៀបធៀប និងប្រើសម្ដីគ្រោតគ្រាតជាច់អហង្កាទាំងអស់។

បុរសវ័យកណ្ដាលមនុស្ស យំស្រក់ទឹកភ្នែកប៉ាត់ៗនឹកដល់កូនស្រីកំពូលចិត្ត... ខ្សែភ្នែករបស់សិស្សសាលាជាច្រើននាក់ ដែលដើរឆ្លងកាត់ទៅមកសុទ្ធតែសម្លឹងមកគាត់ ដោយក្ដីអាណោចអាធ័ម។ ពេលនេះគាត់លែងខ្វល់នឹងកិត្តយស កេរ្ដិ៍ឈ្មោះ និងមុខមាត់របស់វង្សត្រកូលតទៅទៀតហើយ...

ព្រោះទោះជាឲ្យគាត់ មានរបស់អស់នោះខ្ពស់រហូតទល់មេឃ... ក៏វាមិនអាចធ្វើឲ្យកូនស្រីតែម្នាក់របស់គាត់ត្រលប់មកស្ថិតនៅក្នុងលង្វែកទ្រូងរបស់គាត់វិញដែរ។

* * *

ក្នុងទីកន្លែងដែលមានតែភ្លើងពណ៌ កកកុញ ណែនណាន់ តាន់តាប់ ទៅដោយមនុស្សម្នានៅពេញបន្ទប់តូចៗទាំងអស់ក្នុងទីកន្លែងនេះ មានទាំងស្រាបៀរ ថ្នាំ និងមនុស្សស្រវឹង... ទាំងដែលវាគួរតែជាកន្លែងគ្រោះថ្នាក់សម្រាប់កូនបក្សីតូចដូចរដ្ឋនី... តែនាងបែរជាទទួលអារម្មណ៍ថា វាជាពិភពលោកថ្មីមួយដែលសាងឡើងជាពិសេស សម្រាប់មនុស្សមានទុក្ខដូចនាង...

រង្គសាល... ទីកន្លែងដ៏សែនមនោរម្យ ក្សេមសុខ សម្រាប់បណ្ដាយុវវ័យទាំងឡាយ។

«បងរ:! អរគុណបងរ:ខ្លាំងណាស់ ដែលធ្វើឲ្យនីបានឃើញពិភពលោកថ្មីៗ ច្រើនយ៉ាងនេះ!» នាងតូចញញឹមដាក់សង្សារកំលោះដោយក្ដីស្នេហា។

តាំងពីនាងរត់ចេញពីផ្ទះមកនៅទីនេះ វីរៈមើលថែនាងយ៉ាងល្អ។ ទង្វើកំលោះធ្វើឲ្យនាងក្រមុំជឿជាក់ទុកចិត្ត ហើយបានត្រៀមកាយត្រៀមចិត្តជាស្រេច ដើម្បីប្រគល់បេះដូងទាំងដួងផ្ញើនឹងគេ។ តែនាងអាចដឹងពីភាពខិលខូចរបស់មនុស្សក្រុមនេះឬអត់...

«បងពេញចិត្តធ្វើដើម្បីអូននីគ្រប់យ៉ាងទាំងអស់... បងស្រលាញ់អូននីខ្លាំងណាស់!» គេបាញ់ប្រយោគផ្អែមត្រជាក់ជាក់ត្រចៀកតូចតន់មិនបន្ទូរដៃ។

«បងរះចូលចិត្តនិយាយបែបនេះដាក់នីរហូត អត់ដឹងទេឬថានីអៀន!» នាងធ្វើជាបួញមាត់ដាក់សង្សារគួរឲ្យស្រលាញ់។

«អូននី! យ៉ាងណាយើងក៏ស្គាល់គ្នាយូរមកហើយ បងមានអ្វីចង់ឲ្យអូនជួយបន្តិច!» វីរៈធ្វើជាលូកហោប៉ៅយករបស់ម្យ៉ាងចេញមក។

វាជាគ្រាប់ថ្នាំ...

រដ្ឋនី សួរជាបន្ទាន់ «ថ្នាំអីគេបងរះ? ហេតុអីចាំបាច់ធ្វើលឹបលដល់ថ្នាក់នេះ?»

«វីតាមីនស៊ី!» គេកុហក «គឺបងប្អូនរបស់បងបង្កើត ក្រុមហ៊ុន ផលិតវីតាមីនស៊ី ហើយផ្ញើបងឲ្យជួយលក់... ពិសេសពេលនេះបានផលចំណេញខ្ពស់ណាស់! នីជួយយកទៅចែកចាយឲ្យម៉ូយគ្រប់គ្នាតាមក្រដាសនេះផងបានទេ?» គេហុចក្រដាសបញ្ជីឈ្មោះមួយសន្លឹកឲ្យ «បងពិតជាជាប់រវល់មិនអាចបញ្ជូនវីតាមីនស៊ីទៅឲ្យគេបានទាន់ពេលទេ!»

នាងក្រមុំសម្លឹងយ៉ាងរិះគិត មុននឹងសម្រេចចិត្តឆ្លើយយល់ព្រម ព្រោះសេចក្ដីទុកចិត្ត។

រដ្ឋនី ចាប់ផ្ដើមចេញចែកចាយគ្រាប់ថ្នាំក្នុងនាមជាវីតាមីនស៊ី ទៅគ្រប់ទីកន្លែងតាមអាសយដ្ឋាននៅក្នុងបញ្ជីឈ្មោះនោះរៀងរាល់ថ្ងៃ។ នាងមិនធ្លាប់សង្ស័យ ឬនឹកឆ្ងល់អ្វីឡើយថាថ្នាំនេះមិនមែនជាវីតាមីនស៊ី។

ម៉ូយដែលកម្មង់ទិញវីតាមីនស៊ី ភាគច្រើនសុទ្ធតែមានរូបរាងស្គមស្គាំង ទឹកមុខស្លក់ខ្មៅ ភ្នែកស្រអាប់... ផ្ទុយពីនាងមិនសង្ស័យថា ហេតុអ្វីទើបដូច្នោះ បែរជាគិតថា បើពួកគេទិញវីតាមីនស៊ីទៅលេបជាប្រចាំ ប្រហែលជាអាចធ្វើឲ្យរាងកាយរឹងមាំឡើងវិញបាន ទើបនាងលក់ផងថែមឲ្យផង ដោយមិនខកខានមួយពេលណាឡើយ។

* * *

ច្រើនថ្ងៃបន្ទាប់មក...

«លោកប៉ូលីស មានបានទទួលតម្រុយអ្វីពីកូនស្រីរបស់ខ្ញុំខ្លះទេ ក្មេងស្រីដែលឈ្មោះរដ្ឋនីនោះអី?» លោកប្រសិទ្ធិរត់ចូលទៅសួរក្នុងទីស្នាក់ការប៉ូលីសដោយក្ដីអន្ទះអន្ទែង។

ច្រើនថ្ងៃមកហើយដែលជីវិតរបស់គាត់ប្រែប្រួលតាំងពីគ្មានកូន... ប្រែពីធ្លាប់ជេរប្រទេចកូនរាល់ថ្ងៃព្រឹកល្ងាច ត្រលប់មកជាអង្គុយធ្វើមុខសោកសៅម្នាក់ឯង យ៉ាងស្ងៀមស្ងាត់នៅក្នុងផ្ទះ។

ទោះបីជាខំតាមរករដ្ឋនីទាំងយប់ទាំងថ្ងៃ រហូតស្ទើរតែមិនបានស៊ីមិនបានដេក... ក៏គាត់នៅតែមិនបានជួបរដ្ឋនីម្ដងណាសោះ... ទង្វើរបស់គាត់នៅយប់នោះ បានត្រលប់ចូលមកញ៉ាំញីផ្លូវចិត្តគាត់

ម្តងហើយម្តងមិនឈប់ឈរ... ភារកិច្ចការងារ ឋានៈតំណែងមុខមាត់ក្នុងសង្គម ក៏ស្រកស្រុតចុះជាលំដាប់។ គាត់គ្មានពេលសូម្បីតែឈាងចូលទៅមើល មូលនិធិក្មេងកំព្រារបស់ខ្លួន។

«ពេលនេះប៉ូលីសទទួលបានតម្រុយមកថា នាងអាចនឹងកំពុងស្នាក់នៅជាមួយបក្សពួកជួញដូរគ្រឿងញៀនរបស់នាយវីរៈ ដែលជាមុខសញ្ញាចាស់របស់ប៉ូលីស!» ប៉ូលីសនិយាយចេញមកដោយក្តីតានតឹង «ខ្ញុំគិតថា... ជួនកាលកូនស្រីរបស់លោកកំពុងរស់នៅជាមួយនាយវីរៈក៏ថាបាន!»

លោកប្រសិទ្ធិ៍ បើកភ្នែកធំៗញញឹមដោយក្តីត្រេកអរ «ពិតឬលោកប៉ូលីស?... ចុះលោកប៉ូលីសអាចប្រាប់បានទេថា នាយវីរៈម្នាក់នោះជានរណា? ហើយពេលនេះស្នាក់នៅឯណា?... ខ្ញុំចង់បានកូនស្រីរបស់ខ្ញុំត្រលប់មកវិញពេញទំហឹងហើយ!»

«ធ្វើចិត្តឲ្យត្រជាក់សិនទៅលោក ទុកតួនាទីនេះឲ្យខាងប៉ូលីសជាអ្នកដោះស្រាយចុះ បើចិត្តក្តៅពេកក៏មិនបានជួយអ្វីឲ្យល្អប្រសើរដែរ!»

គាត់ស្ងប់អារម្មណ៍។ សម្តីរបស់ប៉ូលីស ធ្វើឲ្យគាត់នឹកឃើញហេតុការណ៍យប់នោះម្តងទៀត... បើគាត់មិនចិត្តក្តៅ រឿងបែបនេះក៏ប្រហែលជាមិនកើតឡើងដែរ។

យប់នេះ ខាងប៉ូលីសមានគម្រោងសម្រុកចូលវង្គសាលងងឹតនោះ យ៉ាងសម្ងាត់។

* * *

«ដើរលក់វីតាមីនស៊ីទៀតហើយឬ?» នាងធ្វើមុខជុញទ្រាន់ដាក់សង្សារ «នីដើរចែកចាយឲ្យម៉ូយពេញមួយថ្ងៃហើយ ហត់ខ្លាំងណាស់! នីសុំសម្រាកសិនណា... ចាំថ្ងៃស្អែកសឹមទៅទៀត!»

ស្រស់ស្រី អង្វរករសង្សារនៅមុខវង្គសាល។ ដៃតោងបុរសជាប់ ដូចកូនក្មេងកំពុងអង្វរមនុស្សចាស់។

វីរៈដកដង្ហើមធំលាន់សូរឃ្យូរ សម្លឹងមុខតូចតន់យ៉ាងទើសទាល់ «កុំក្បាច់ក្បូរច្រើនពេក គិតថាខ្លួនឯងគួរឲ្យស្រលាញ់ណាស់ឬ បានជាមានសិទ្ធិរើស? យើងមានការងារឲ្យធ្វើក៏ធ្វើទៅ ធំៗអស់ហើយល្មមជួយគ្នាធ្វើការរកស៊ីបានខ្លះហើយ!» សម្តីរបស់គេខុសប្លែកពីពេលថ្មីៗស្រឡះ។

«ហេតុអីក៏និយាយបែបនេះបងរៈ?» នាងងឿងឆ្ងល់ «មិនល្អទេ និយាយបែបនេះមិនសុភាពសោះ!»

«យើងគឺបែបនេះឯង!» គេគំហកខ្លាំងៗគំរាមស្រស់ស្រី «ប្រញាប់យកថ្នាំទៅឲ្យម៉ូយទៅ បើមិនអ៊ីចឹងជួបរឿងល្អមើលមិនខាន!»

«ជួបរឿងល្អមើលអី?» នាងជ្រួញចិញ្ចើមធ្វើមុខស្អុយ... គិតថាវីរៈនឹងលួង។

«គឺលក់ខ្លួននោះអី! បើគ្រាន់តែជួយគ្នាយកថ្នាំទៅឲ្យម៉ូយប៉ុណ្ណឹងមិនបាន ច្បាស់ជាត្រូវទៅលក់ខ្លួនយកលុយមកស៊ីចាយហើយ!»

«អ្ហះ! ម៉េចក៏បងវីរៈនិយាយជាមួយនីបែបនេះ? នីជាប្រពន្ធរបស់បងណា!» នាងស្រឡាំងកាំងកាន់តែខ្លាំង... ខ្សែភ្នែកដែលធ្លាប់តែស្រទន់របស់គេ ត្រលប់ក្លាយជាខ្សែភ្នែកកោងកាច។ ពីមនុស្សដែលធ្លាប់ល្អសែនល្អ ហេតុអ្វីគេនិយាយបែបនេះដាក់នាងកើត?

«ប្រពន្ធឬ? មនុស្សស្រីដូចនាងគ្មានគុណសម្បត្តិ មកធ្វើជាម៉ែរបស់កូនយើងទេ!» គេពេបមាត់ញញឹមចំអកគួរឲ្យខ្លាច «ចាំទុកក្នុងខួរក្បាលរបស់នាងទៅ ថា សង្គមតាមអ៊ីនធើណេត ជាសង្គមដែលប្រើខួរក្បាល ប្រើការគិត ប្រើវិចារណញ្ញាណ... តែបើល្ងង់ដូចនាង ច្បាស់ជាត្រូវគេបោកបែបនេះឯង!»

និយាយចប់ វីរៈក៏ដើរចេញវឹងពីខ្សែភ្នែករបស់នាង។

រដ្ឋនី ស្រឡាំងកាំងនឹងការប្រែប្រួលរបស់សង្សារ។ នាងចាំបាច់ត្រូវតែព្រមយកវីតាមីនស៊ីទៅចែកចាយបន្ត ទោះបីជាហត់នឿយយ៉ាងណាក៏ដោយ។ ទោះយ៉ាងណាក៏នាងគ្មានថ្ងៃទៅលក់ខ្លួនជាដាច់ខាត។

...បើទោះជានាងមិនមែនជា កុលស្ត្រីដែលល្អប៉ុន្មានក៏ដោយ តែក៏មិនមែនចេះតែបណ្ដោយខ្លួនបណ្ដោយប្រាណឲ្យភ្លើតភ្លើនតាមភ្លើងពណ៌ក្នុងទីក្រុងធំបែបនេះដែរ។

* * *

ប៉ូលីសចាប់ផ្ដើមផែនការ ចេញចាប់ក្រុមអន្ធពាលនៅក្នុងវង្គសាលនេះ ពីបទឃុំឃាំងមនុស្ស និងមានការផលិតថ្នាំយ៉ាបា...

លោកប្រសិទ្ធិ៍ ដើរតាមផែនការរបស់ប៉ូលីសយ៉ាងចិត្តត្រជាក់... ទោះបីជានៅក្នុងចិត្តនឹកបារម្ភពីកូនស្រីខ្លួនឯងខ្លាំងយ៉ាងណាក៏ខំអត់ទ្រាំ។

«ហ៊ឺយ! ប៉ូលីសមកហើយវ៉ឺយ!!!» វីរៈស្រែកបង្ហកខ្ទរវង្គសាល នៅពេលឃើញក្រុមប៉ូលីសសម្រុកចូលមក។

រំពេចនោះ ក៏កើតមានការប៉ះទង្គិចអាវុធយ៉ាងខ្លាំងក្លា រហូតធ្វើឲ្យរបស់របរនៅក្នុងវង្គសាលធ្លាក់បែកខ្ចាត់ខ្ចាយគ្មានសល់។ យុវវ័យប្រុសស្រីជាច្រើននាក់ត្រូវគ្រាប់កាំភ្លើងដួលច្រងាប់ច្រងិលគរលើគ្នា ព្រោះមិនបានប្រុងប្រៀបខ្លួន។

វីរៈបាញ់តបតប៉ូលីសរហូតអស់គ្រាប់កាំភ្លើង។ គេក្រោកឆ្លេឆ្លារត់រកផ្លូវចេញមិនបានក៏យកទូរស័ព្ទចុចហៅរដ្ឋនីជាបន្ទាន់ «នី... អូននី... ជួយបងផង!»

«អាឡូ... បងវីរៈកើតអី?... មានរឿងអីកើតឡើងនៅវង្គសាល ហេតុអីក៏នីឮតែសំឡេងផ្ទុះផាវលាន់បែបនេះ?»

«មិនមែនជាសំឡេងផាវទេនី... កុំប្រញាប់និយាយអីនៅពេលនេះល្អជាង... អូននីត្រូវប្រញាប់បើកឡានមកទទួលបង នៅច្រកចេញខាងក្រោយជាបន្ទាន់ណា!!!» គេបញ្ជា សំឡេងដាច់ខាត មុននឹងចុចបិទទូរស័ព្ទ។

វីរៈរត់គេចពីគ្រាប់កាំភ្លើងរហូតទៅដល់ទ្វារក្រោយ។ គេភ្ញាក់ស្ទើរតែដាច់ផ្លារនៅពេលឃើញក្រុមប៉ូលីសកំពុងឈរយាមនៅច្រកក្រោយដែរ «ហ៊ឹយ!»។

ប៉ូលីសរត់ចូលមកក្រៀកដៃគេជាប់ណែនទាំងសងខាង... ទោះបីកំលោះប្រឹងរើបំរះប្រកែកននៀល នឹងការចាប់ខ្ទាស់របស់ក្រុមប៉ូលីសយ៉ាងណា ក៏មិនអាចដោះខ្លួនបានដែរ «លែងយើង!!!»។

រដ្ឋនី បើកឡានមកដល់ឃើញប៉ូលីសកំពុងចាប់វីរៈល្មម។ នាងគិតថាច្បាស់ជាមានរឿងយល់ច្រឡំអ្វីម្យ៉ាងជាមិនខានទើបរត់ចូលទៅស្រែកឡូឡា។

«លែងបងវីរៈឥឡូវនេះភ្លាម គាត់មិនបានធ្វើអីខុសទេ!» នាងស្រែកដាក់ប៉ូលីស ច្រែតៗ។

លោកប្រសិទ្ធិ ដែលអង្គុយតាមដានហេតុការណ៍នៅក្នុងរថយន្ត ពេលឃើញកូនស្រីខ្លួនឯងលេចមុខនៅកន្លែងកើតហេតុបែបនេះ ក៏ត្រេកអរយ៉ាងខ្លាំង។ គាត់បើកទ្វារចេញមករត់សំដៅរដ្ឋនីជាបន្ទាន់។

«មិនខុសយ៉ាងម៉េច... អារៈនេះហើយ ជាមេក្លោងរបស់ក្រុមជួញដូរគ្រឿងញៀន!» ប៉ូលីសតបសំឡេងធំៗ «បើមិនចង់ជាប់ពាក់ព័ន្ធទេ ចេញឲ្យឆ្ងាយទៅល្អជាង ប៉ារបស់ប្អូនកំពុងតាមសួររកផង!»

ស្រីតូចភ្ញាក់ក្រញាងនៅពេលឮប៉ូលីសរម្លឹកដល់បិតារបស់ខ្លួន។

រំពេចនោះ វីរៈប្រើកែងដៃស៊កប៉ូលីសទាំងពីរនាក់ដាច់ផ្លារតូង... មុននឹងដណ្តើមកាំភ្លើងពីប៉ូលីសយ៉ាងទាន់ហន់។

រដ្ឋនីមិនទាន់បានប្រុងប្រៀបខ្លួនក៏ត្រូវវីរៈចាប់យកធ្វើជាចំណាត់ខ្មាំង។

បុរសជាឪពុកស្រឡាំងកាំងព្រួយបារម្ភពីកូនស្រី «កូននី!!...»

«ប៉ា!» នាងសម្លឹងមុខបិតាយ៉ាងភ្ញាក់ផ្អើល មុននឹងតាំងស្មារតីងាកមកសម្លឹងមុខវីរៈដែលកំពុងឈរភ្ជង់កាំភ្លើងនាងពីក្រោយ «បងរៈ តើរឿងវាយ៉ាងម៉េច?» នាងសួរសំឡេងញ័រ។

«បិទមាត់ទៅ! ហើយចាំធ្វើតាមបញ្ជារបស់យើង!» គេគំរាមនាងសំឡេងមាំ។

លោកប្រសិទ្ធិ ទ្រាំឈរសម្លឹងមើលកូនស្រីខ្លួនឯង ត្រូវគេចាប់ធ្វើចំណាត់ខ្មាំងមិនបាន... ក៏រើសយកដំបងឈើនៅលើដីរត់សំដៅចូលទៅជួយដោយមិនគិតពីជីវិតខ្លួនឯង។

វីរៈ ឃើញមានមនុស្សរត់សំដៅចូលមកបម្រុងចាត់ការខ្លួន ក៏បាញ់តម្រង់ក្បាលពោះលោកប្រសិទ្ធិ មួយរំពេច។

នៅចំពោះមុខកូនស្រីបែបនេះ តើនាងអាចទទួលបានទេ?

រដ្ឋនីបំរះខ្លួនចេញ រត់សំដៅទៅរកឪពុកខ្លួនយ៉ាងរហ័ស «លោកប៉ា!»

នៅពេលវីរៈអស់ចំណាត់ខ្មាំង ប៉ូលីសក៏បាញ់សំឡេះវីរៈមួយរំពេច... គេដួលខ្លោកទៅលើដី។

តរុណីនៅក្នុងហេតុការណ៍ យំអណ្តឺតអណ្តកដោយក្តីឈឺចាប់... នាងមានវិប្បដិសារីយ៉ាងខ្លាំង ដែលខ្លួនឯងជាដើមហេតុធ្វើឲ្យឪពុកត្រូវគ្រាប់នៅថ្ងៃនេះ។

«លោកប៉ា... លោកប៉ាកុំកើតអីណា... នីនៅទីនេះហើយ! នីសុំទោសសម្រាប់រឿងគ្រប់យ៉ាង... នីទើបតែដឹងថា ប៉ាស្រលាញ់កូនខ្លាំងប៉ុណ្ណា... ប៉ារត់ចូលមកជួយនីដោយមិនខ្លាចអ្វីសោះ!» នាងខ្សឹកខ្សួល។

«កុំបន្ទោសខ្លួនឯងអីកូន... កុំយំ...» គាត់ជូតទឹកភ្នែកឲ្យកូនស្រីដោយក្ដីស្រលាញ់ «កូនមិនខុសទេ... ប៉ាខុសដោយខ្លួនឯងដែលមើលមិនឃើញលក្ខណៈពិសេសរបស់កូន! ប៉ាខុសដោយខ្លួនឯងដែលតែងតែធ្វើឲ្យកូនឈឺចិត្តរហូតមក... ប៉ាខុសដោយខ្លួនឯងដែលចិញ្ចឹមកូនខុសទាំងងងឹតងងុល...» សំឡេងស្អកដាច់ៗ ប្រឹងនិយាយចេញពីបំពង់ក របស់បុរសជាឪពុក។

«លោកប៉ា... កូនស្រលាញ់លោកប៉ាណា... កូនទទួលស្គាល់ថា កូនជាក្មេងរឹងរូសក្បាលរឹង ការរៀនសូត្រខ្សោយ! នីសន្យាថា នីត្រូវតែល្អជាងនេះឲ្យបាន... សុំត្រឹមតែប៉ានៅជាមួយកូនណា!» នាងក្រសោបបិតាយ៉ាងណែន ដៃក្ដោបដៃគ្នាទៅវិញទៅមកយ៉ាងកក់ក្ដៅ។

«ប៉ាក៏ស្រលាញ់កូនដែរ កុំកង្វល់អី ប៉ាគង់តែនឹងជាទេ... កុំយំអីកូនស្រីប៉ា!» គាត់ព្យាយាមញញឹមដាក់កូន «ប៉ាធ្លាប់គិតថា ការដែលប៉ាខំប្រឹងប្រែងធ្វើការ ស្រវាចាប់យកមុខតំណែងធំៗមកទុក ... អ្វីទាំងអស់នោះប៉ាធ្វើដើម្បីកូន ដើម្បីគ្រួសារ... តែប៉ាមិនធ្លាប់សួរកូនសោះថា កូនត្រូវការវាឬអត់?»

«កុំខំនិយាយអីលោកប៉ា...»

«ឲ្យប៉ាបាននិយាយជាលើកចុងក្រោយចុះ!» គាត់ឈឺចុកចាប់ពេញមុខរបួស តែក៏ព្យាយាមអត់ទ្រាំការឈឺចាប់នោះមិនឲ្យកូនឃើញ «ប៉ាសុំទោស... ដែលចូលចិត្តនិយាយថា កូនគ្មានលក្ខណៈជាកុលស្ត្រី... តែពេលនេះប៉ាដឹងហើយថា អ្វីដែលប៉ានិយាយនោះខុសស្រឡះ... កូនមានលក្ខណៈជាកុលស្ត្រីច្រើនណាស់ ច្រើនជាងប៉ាគិតទុកទៅទៀត! ពេលនេះកូនបានពិសោធន៍ឲ្យប៉ាឃើញហើយ... ថាភាពជាកុលស្ត្រីនោះគឺស្ថិតនៅលើចិត្ត! ន័យពិតរបស់ពាក្យថាកុលស្ត្រី... មិនមែនសម្ដែងចេញតែសម្បកក្រៅទេ!» គាត់ញញឹមដាក់កូនស្រីខ្លួនឯង ដោយក្ដីស្រលាញ់ដែលពេញប្រៀប «នី... ប៉ាស្រលាញ់កូនខ្លាំងណាស់!»

និយាយចប់ លោកប្រសិទ្ធិ៍ ក៏ផុតដង្ហើមក្នុងរង្វង់ដៃរបស់កូនស្រី។ ភាពកក់ក្ដៅដែលនាងបានទទួលនៅពេលនេះ គង់ជាលើកចុងក្រោយនៃជីវិតរបស់នាងហើយ។

រយៈពេលកន្លងមក រដ្ឋនីជាក្មេងស្រីដែលកំព្រាម្ដាយ ទើបភាពជាកុលស្ត្រីរបស់នាងមិនបានទទួលការបង្ហាត់បង្ហាញ ឲ្យសម្ដែងចេញមកដោយត្រង់ដូចក្មេងផ្សេងៗទៀត។ តែទោះបីជានាងមិនបានទទួលការចិញ្ចឹមបីបាច់ល្អដូចគេឯង ក៏នាងអាចទទួលដឹងខ្លះៗនូវសេចក្ដីស្រលាញ់ដែលឪពុកខ្លួនបញ្ជូនមកឲ្យតាមរយៈខ្សែភ្នែកដែរ... នាងទើបតែដឹងនៅថ្ងៃចុងក្រោយ!

... ថ្ងៃដែលគ្មានការឈ្លោះគ្នានៅក្នុងគ្រួសារ។

... ថ្ងៃដែលមានតែសេចក្ដីស្រលាញ់... ថ្ងៃដែលមានតែការយល់ចិត្តគ្នា។

... ទម្រាំតែដល់ថ្ងៃនេះ... នរណាទៅដឹងថា វាជាថ្ងៃចុងក្រោយ...

០១ឧសភា២០១១